
SOVRIN®
JUNE 2012
CONTEMPORARY DESIGNER, LY PISITH
5 BEST HOMECOOK RESTAURANTS
បាត់ដំបង
សម័យអ្នកនាងម្ចាស់
វិលទៅរកអតីតកាលដ៏អស្ចារ្យជាមួយនឹង
កញ្ញា DAPHNEE LUCENET
JUNE 2012 8000 Riel | USD 2
89
9 771800 87033 2



# *The* EDITOR'S NOTE

សំណង់អគារបុរាណបែប Colonial House កាលពីសម័យអាណានិគមនិយមបារាំងពិតជាមានភាពទាក់ទាញ និងជាប្រវត្តិសាស្រ្តសម្រាប់ខ្មែរយើង។ បាត់ដំបង ជាខេត្តមួយដែលសម្បូរទៅដោយសំណង់អគារទាំងនេះ ហើយក៏ជាទីក្រុងចំណាស់មួយដែលបន្សល់ទុកនូវហេដ្ឋារចនាសម្ព័នបុរាណបានល្អ វាមើលទៅពិតជាមានអារម្មណ៍ថាឋិតនៅក្នុងសម័យបុរាណដូច្នោះ។ ទោះបីសំណង់ទាំងនោះចាស់ក៏ពិតមែន ប៉ុន្តែនៅតែទាក់ភ្នែកមិនចាញ់ពីសម័យមុននោះទេ។ SOVRIN សូមនាំលោកអ្នកទៅកាន់ពិភពហ្វេហ្សិនកាលពីសម័យអាណានិគមនិយមបារាំង ជាមួយនឹងកញ្ញា Daphnee ដែលជាកូនកាត់ខ្មែរបារាំងរួមនឹងទិដ្ឋភាពដ៏ស្រស់បំព្រងនាខេត្តបាត់ដំបង។ ជាមួយលេខទី៩ នេះដែរ SOVRIN នឹងណែនាំលោកអ្នកអោយស្គាល់លោក John McDermott សិល្បករថតរូបអាមេរិកដែលនិយមផ្តិតយករូបភាពដួងព្រលឹងអង្គរ អ្នកច្នៃម៉ូដគ្រឿងអលង្ការប្រាក់ខ្មែរធ្វើដោយដៃលោក Ly Pisith អ្នកអភិរក្សរបាំខ្មែរនាទឹកដីអង្គរលោកជំទាវ កន្ទាំរ៉ាវីន ងិនការ៉េត។ បទសម្ភាសជាមួយអ្នកនាង គង់សុជាតិ ពីស្ពាដៃតុបតែងមុខ និងសក់ដ៏ប៉ិនប្រសព្វ កញ្ញា ប៊ីវីយា តារាកូនកាត់តណ្ហាដែលកំពុងរះ។ SOVRIN ក៏បានផ្តល់នូវចំនេះដឹង និងតិចនិចស្តីអំពីការថៃរក្សាកែងជើងប្រេះ បញ្ហាមហារីកស្បែក។ល។ រួមជាមួយនឹងផលិតផលថៃសម្អស្សជាច្រើនប្រភេទទៀត។ សម្រាប់ខែមិថុនានេះ SOVRIN នឹងដឹកនាំលោកអ្នកទៅកាន់ទីលំហែកាយដ៏មានប្រជាប្រិយភាព គឺតំបន់ទេសចរណ៍សមុទ្រពិភពលោក ខេត្តព្រះសីហនុ។

សូមរីករាយជាមួយ SOVRIN ទាំងអស់គ្នា!
ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់

នាយកនិពន្ធ

លី ស៊ូដេន


SOVRIN
FASHION
62
បាត់ដំបងសម័យ
អ្នកនាងម្ចាស់
ធ្វើដំណើរវិលទៅរក
អតីតកាលដ៏អស្ចារ្យ



Feathers and Gems on One Shoulder Black Top **AXARA** $183.00, Black Sequin Skinny Pants **AXARA** $99.00, Big Golden Coin Bracelet Watch **VNC** $25.00, Black Peep-Toe Flatform High Heels **VNC** $49.00



# បាត់ដំបង សម័យអ្នកនាងម្ចាស់

ធ្វើដំណើរវិលទៅរកអតីតកាលដ៏អស្ចារ្យ
ជាមួយនឹងរតនៈសម្បត្តិដែលមិនអាចកាត់ថ្លៃបាន
នៅក្នុងទឹកដីខេត្តបាត់ដំបងនៃប្រទេសកម្ពុជា
ព្រះរាជាណាចក្រអច្ឆរិយរបស់យើង

PHOTOGRAPHY : ***CHEM VUTH SOVIN & ALEX TEE***
MAKE UP & HAIR : ***KENZO***
MANICURE & PEDICURE : ***DE.GRAN JAPAN***
MODEL : ***DAPHNEE LUCENET***
LOCATION : ***BATTAMBANG PROVINCE***



Beige Silk Top with Black Tie **LE MARAIS** $269.00, Brown Baggy Waist Pants **LE MARAIS** $99.00, Black Women Style Watch **VNC** $13.00, Big Black Leather Golden Lock Bag **VNC** $59.00, Double Golden Buckles Heeled Sandals **VNC** $45.00



Black Shinny V-Neck Knit Dress **MANGO** $49.90, Ethnic Loops Earrings **LE MARAIS**, Purple High Heels **VNC** $45.00,

# តាមរយៈ

ការណែនាំពី Plusmax ក្រុមការងារ SOVRIN ក៏បានស្គាល់កញ្ញា Daphnee ដែលជាតារាបង្ហាញម៉ូដកូនកាត់សញ្ជាតិ ខ្មែរ-បារាំង ដ៏ស្រស់សោភា។ នាងមានរូបរាង និងកំពស់លេចធ្លោតាមបែបនារីអឺរ៉ុប ក៏ប៉ុន្តែបើគន់អោយយូរទៅយើងអាចកត់សំគាល់បាននូវទម្រង់មុខបែបនារីខ្មែរដែលកាត់ទៅតាមម្ដាយ។

ដោយមិនមានភាពស្ទាក់ស្ទើរ យើងក៏បានអញ្ជើញ Daphnee ចូលរួមថតជាតារាក្របមុខប្រចាំខែមិថុនា។ ការថតរូបរបស់យើងបានចាប់ផ្ដើមនៅលើទឹកដីខេត្តបាត់ដំបងដែលគឺជាអាណាខេត្តចំណាស់មួយនៅប្រទេសកម្ពុជា។ Daphnee បានបង្ហាញរូបសម្ផស្សដ៏ឆើតឆាយរបស់នាងនៅចំពីមុខកាំមេរ៉ារបស់យើងប្រកបដោយភាពស្ទាត់ជំនាញ ព្រោះតែនាងគឺជាតារាបង្ហាញម៉ូដស្រាប់។ បទពិសោធន៍ក្នុងការថតរូបកន្លងមកអាចធ្វើអោយតារាកូនកាត់រូបនេះរបស់នាងមិនមែនមានត្រឹមតែរូបសម្រស់ទេ គឺគួបផ្សំទាំងសមត្ថភាពនិងអត្តចរិតរួសរាយរាក់ទាក់ផងដែរ។

នាងបានធំដឹងក្ដីនៅក្នុងប្រទេសបារាំងដែលជាប្រទេសកំណើតឪពុកនាង។ Daphnee បានបញ្ចប់ការសិក្សាផ្នែកវិស្វករ ព័ត៌មានវិទ្យា និងកំពុងបម្រើការងារដែលពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មអន្តរជាតិ។ អាជីពជាតារាបង្ហាញម៉ូដរបស់នាងបានចាប់ផ្ដើមកាលពី ២ ឆ្នាំមុន។ Daphnee បានពោលមកកាន់យើងថា "ខ្ញុំបានជាប់ជាបវរកញ្ញាកម្ពុជាសំរាប់ចំណាត់ថ្នាក់លេខ ២ នៅប្រទេសបារាំង ក្នុងឆ្នាំ ២០១០។ ផ្ដើមពីតំណែងនេះខ្ញុំក៏ត្រូវបានក្រុមហ៊ុនបង្ហាញម៉ូដនានាទាក់ទងអោយដើរបង្ហាញម៉ូដជាបន្តបន្ទាប់។ ក្រៅពីនេះខ្ញុំក៏បានចូលរួមសម្ដែងក្នុងខ្សែភាពយន្តខ្លី និងស្ប៉ុតពាណិជ្ជកម្មផ្សេងៗផងដែរ"។ SOVRIN មិនមែនជាទស្សនាវដ្ដី Fashion ទី ១ ដែល Daphnee បានបង្ហាញមុខនោះ ទេ។ នាងបានបន្តប្រាប់យើងដោយស្នាមញញឹមរាក់ទាក់ "នាងខ្ញុំធ្លាប់បថតអោយទស្សនាវដ្ដី GQ និង ELLE ហើយធ្លាប់ធ្វើការអោយម៉ាកល្បីៗជាច្រើនដែលមានដូចជា Nike, Hennessy, និង Pantene" ។

កាន់តែសំណេះសំណាលយើងកាន់តែចាប់អារម្មណ៍ចំពោះនារីកូនកាត់រូបនេះ។ នាងហាក់បីដូចជាពូកែស្ទើរគ្រប់ជំនាញ មិនថាតែការងារពាណិជ្ជកម្ម បង្ហាញម៉ូដ តន្ត្រី និងសូម្បីតែក្បាច់គុណ។ យើងបានអស់សំណើចបន្តិចនៅពេលដែលលឺនាងប្រាប់ថានាងធ្លាប់បានធ្វើដំណើរទៅរៀនកុងហ្វូនៅប្រទេសចិនរយៈពេល ៣ ខែ។ Daphnee បានពន្យល់ថា " ក្ដីស្រមៃរបស់ខ្ញុំគឺអាចធ្វើអោយក្រុមគ្រួសារមានរបស់ខ្ញុំមោទនភាព។ ខ្ញុំចង់ចេះជំនាញគ្រប់មុខតាមដែលអាចធ្វើបាន។ ខ្ញុំចូលចិត្តច្រៀង និងលេងហ្គីតាហើយខ្ញុំក៏អាចតែងចម្រៀងបានផងដែរ។ ចំពោះកីឡាវិញខ្ញុំធ្លាប់ចូលរួមប្រកួតប្រជែងក្នុងកីឡាប្រណាំងហែលទឹក និងជិះស្គី។ សូម្បីតែប្រដាល់ក៏ជាចំណូលចិត្តរបស់ខ្ញុំដែរ" ។ របៀបរបបរស់នៅតាមបែបបទអឺរ៉ុប ដែលសម្បូរទៅដោយប្រភេទអាហារមានជាតិកាឡូរីច្រើន ធ្វើអោយ Daphnee មានការយកចិត្តទុកដាក់ជាពិសេសក្នុងការទទួលទាន។ នៅកម្ពុជា នាងអាចមានសេរីភាពភ្លក្សរសជាតិអាហារគ្រប់មុខតាមចិត្តចង់។ ប៉ុន្តែនៅប៉ារីសនាងត្រូវព្យាយាមជៀសវាងអាហារណាដែលងាយធ្វើអោយធាត់ដូចជា ភីហ្សា គ្រឿងស្រវឹង សូដា ហើយជំនួសដោយការញុាំទឹកតែអោយបានច្រើន។ នាងក៏មានទម្លាប់ចូលចិត្តអាហារអាស៊ីជាជាងអាហារអឺរ៉ុប ជាពិសេសគឺស៊ូស៊ីរបស់ជប៉ុន។

បើសិនជានិយាយពីការថែរក្សាសម្ផស្សវិញអ្វីដែលនាងមិនអាចខ្វះបានគឺឡេផ្ដល់ជាតិសំណើម។ នាងមិនដែលភ្លេចទេនូវការលាបឡេផ្ដល់សំណើមដល់ដៃគ្រប់ពេលដែលលាងសំអាតដៃនោះទេ។ ស្បែករបស់ Daphnee ឆាប់ទទួលរងប្រតិកម្មបន្តិច ដូច្នេះនាងជ្រើសរើសប្រើប្រភេទសាប៊ូ និងឡេដែលមានផ្សំពីសារធាតុមិនខ្លាំងពេក។ នាងបានបញ្ជាក់ទៀតថា "ចំពោះស្បែកមុខ ខ្ញុំអនុវត្តតាមការណែនាំរបស់គ្រូពេទ្យគឺលាងសំអាត និងផ្ដល់សំណើមខ្ញុំក៏ឧស្សាហ៍ Scrub មុខដែរគឺ ២ទៅ ៣ ដងក្នុងមួយសប្ដាហ៍។ ផលិតផលដែលខ្ញុំចូលចិត្តប្រើនោះគឺ Clinique, Avène, Neutrogena, Nivea, និង Garancia។ ការធាត់មុខមិនមែន




“I do love
everything in
Cambodia”



Black Heart Breast Line Slim Fit Dress **MANGO** $59.90, Black Tassel Hem Thread Net Cardigan **Eric Raisina** $325.00, Multi Size Metal Balls Necklace **Ambre**



ជាទម្លាប់ជាប្រចាំរបស់ Daphnee ទេ " ។ នាងផាត់មុខតែពេលដើរកំសាន្ត ឬជួបជុំមិត្តភក្តិតែប៉ុណ្ណោះ។ បើពេលទៅថតរូបធ្វើតេស្តកាំម៉េរ៉ាវិញ នាងចូលចិត្តទៅជាលក្ខណៈធម្មជាតិច្រើនជាង។ Daphnee បានពន្យល់ថា "ប្រសិនបើអ្នកទៅធ្វើតេស្តកាំម៉េរ៉ាដោយផាត់មុខក្រាស់ៗនោះ អ្នកនឹងមិនត្រូវបានជ្រើសរើសនោះទេ។ វាត្រូវបានចាត់ទុកថាជារឿងដែលគេមិនពេញនិយមទេនៅបារាំង"។ Daphnee ក៏បានបង្ហើបប្រាប់យើងនូវអាថ៌កំបាំងផ្ទាល់ខ្លួនមួយផងដែរថា "ខ្ញុំយកចិត្តទុកដាក់ជាងគេគឺធ្មេញ។ នៅក្នុងមួយសប្តាហ៍ ខ្ញុំប្រើម្សៅសូដ្យូមប៊ីកាបូណាតធ្វើអោយធ្មេញសយ៉ាងហោចណាស់ក៏ម្តងដែរ។ ហើយបើសិនខ្ញុំមុតត្រូវនឹងអ្វីវិញ ខ្ញុំតែងតែប្រើទឹកឃ្មុំ ព្រោះវាមានប្រសិទ្ធភាពក្នុងការបំបាត់សន្លាកតាមបែបធម្មជាតិ"។

ពិភព Fashion របស់ Daphnee គឺខុសប្លែកពីគេ។ នាងមិនចូលចិត្តបង្ហាញភាពលេចធ្លោជាមួយនឹងស្បែកជើងកែងអេស្កាបុាំងដូចតារាបង្ហាញម៉ូដផ្សេងទៀតនោះទេ។ នាងក៏មិនចូលចិត្តដេញតាមម៉ូដនិយមថ្មីពេកដែរ។ Daphnee បានប្រាប់អោយដឹងថា "ខ្ញុំតែងតែចាប់អារម្មណ៍ជាមួយម៉ូដទាន់សម័យថ្មីៗប៉ុន្តែខ្ញុំប្រកាន់យក Fashion ផ្ទាល់ខ្លួនរបស់ខ្ញុំ។ ខ្ញុំនៅតែស្លៀកខោដែលខ្ញុំធ្លាប់ស្លៀកតាំងពីអាយុ ១៥ ឆ្នាំ ខ្ញុំក៏រួមបញ្ចូលស្ទីលតាមចំណូលចិត្ត។ ពេលខ្លះប្រសិនបើម៉ូដដែលខ្ញុំស្រលាញ់មានមនុស្សពាក់ច្រើនពេក ខ្ញុំចាំរហូតដល់គេឈប់ពេញនិយមទើបទិញក៏មាន។ ខ្ញុំមិនចូលចិត្តពាក់អ្វីដែលនរណាៗក៏មាននោះទេ។ រីឯស្ទីលប្រចាំថ្ងៃរបស់ខ្ញុំគឺជាអាវយឺតពណ៌លាតជាមួយនឹងខោខូវប៊ិយនិងអាវធំបែប Classy ឬក៏អាវធំស្បែក បន្ថែមជាមួយនឹងស្បែកជើងដែលមានផាសុកភាពក្នុងការពាក់។ Daphnee ក៏ចូលចិត្តតុបតែងខ្លួនជាមួយនឹងគ្រឿង Accessories ដូចជាខ្សែដៃស្បែក ចិញ្ចៀនធំ ខ្សែក ក្រវិល។ នាងយល់ថា ការពាក់តិចគឺល្អបំផុត។ អ្នកមិនចាំបាច់ពាក់ស្អែកស្អះច្រើនពេកនោះទេ។

ដោយសារតែនេះគឺជាលើកទី ៩ របស់ Daphnee នៅលើទឹកដីកំណើតរបស់អ្នកម្តាយនាង យើងហាក់បីដូចជាចង់ដឹងខ្លាំងណាស់ពីការយល់ឃើញរបស់នាងផ្ទាល់ចំពោះកម្ពុជា។ ដោយសាច់ញាតិរបស់នាងស្ថិតនៅសៀមរាបស្រាប់ Daphnee មានឱកាសទៅលេងអង្គរវត្តជាច្រើនដង។ នាងបានពោលបញ្ជាក់ដោយអារម្មណ៍រំភើបថា "ខ្ញុំបានទៅប្រាសាទអង្គរវត្តមិនតិចជាង១០ ដងទេ។ បើសម្លឹងមើលលើអច្ឆរិយភាពនៃប្រាង្គប្រាសាទនេះ នាងខ្ញុំពិតជារំភើបណាស់ដែលអាចមានអ្នកម៉ាក់ជាជនជាតិខ្មែរដែលធ្វើអោយខ្ញុំក្លាយជាកូនចៅនៃអ្នកដែលសាងអង្គរដែរ"។ ក្រៅពីដើរកំសាន្ត Daphnee បានរួមចំណែកជួយដល់វិស័យអប់រំក្នុងកម្ពុជាដែរ។ ក្នុងរយៈពេលនេះនាងបានទៅទស្សនកិច្ច និងជួយដល់សាលានៅវ៉ារិនដែលនាងនឹងក្រុមមិត្តភក្តិដែលមកពីសមាគមសប្បុរសធម៌នៃសាលាវិស្វកររបស់នាងធ្លាប់បានជួយផ្តល់បន្ទះសូឡាកាលពីឆ្នាំ ២០១០។ នាងក៏បានជួបឧបត្ថម្ភដល់ក្មេងៗនៅខេត្តប៉ៃលិនផងដែរ។ Daphnee បានពន្យល់ថា " ខ្ញុំស្រលាញ់គ្រប់យ៉ាងនៅកម្ពុជា ទាំងប្រវត្តិសាស្ត្រ វប្បធម៌ ម្ហូបអាហារ ប្រជាជន ទេសភាព ហើយព្រមទាំងធនធានធម្មជាតិ"។

អត្ថបទនេះនឹងមិនអាចបញ្ចប់បានទេ ប្រសិនបើ Daphnee មិនទាន់បានប្រាប់យើងពីអារម្មណ៍របស់នាងចំពោះការចូលរួមថតរូបជាមួយ SOVRIN។ ញញឹមបន្តិចនាងបានប្រាប់ដោយមិនស្ទាក់ស្ទើរថា "SOVRIN ផ្តល់អោយខ្ញុំនូវបទពិសោធន៍នៃការថតរូបថ្មីមួយដ៏ពិសេសបំផុតក្នុងអាជីពរបស់ខ្ញុំ។ គ្រប់គ្នាសុទ្ធតែរួសរាយ រហ័សរហួន ហើយមានលក្ខណៈ Professional ពិតៗ។ ខ្ញុំសប្បាយចិត្តដែលមានឱកាសចូលរួមការងារជាមួយនឹងក្រុមល្អៗបែបនេះ។ នាងខ្ញុំទទួលបាននូវអារម្មណ៍កក់ក្តៅជាពិសេស គឺខុសប្លែកពីកាលថតនៅបារាំងឆ្ងាយណាស់។ ក្រុមការងារនៅទីនោះមិនសូវមានភាពរួសរាយទេ។ ម្នាក់ៗគិតតែពីការងារ និងហាក់បីដូចជារក្សាគម្លាតឆ្ងាយពេកនៅក្នុងការទំនាក់ទំនង។ ខ្ញុំចាប់អារម្មណ៍ជាងគេគឺឈុតក្រៅឆាកនៃទស្សនាវដ្តីហើយខ្ញុំពិតជាមានការកោតសរសើរចំពោះស្នាដៃ និងបែបបទក្នុងការគ្រប់គ្រង។ ខ្ញុំពិតជាមានមោទនភាពណាស់ដែលអាចបង្ហាញមុខលើទស្សនាវដ្តី Fashion នៅកម្ពុជានៅក្នុងដំណើរវិវឌ្ឍមកាលមួយនេះ។ SOVRIN បានបង្ហាញនូវសុបិន្តរបស់កម្ពុជាដែលកំពុងរីកចម្រើនជាលំដាប់។ ហើយដោយសារតែការថតលើកនេះ ដែលធ្វើអោយខ្ញុំបានស្គាល់ទឹកដីបាត់ដំបងជាលើកទី ១។ បើទោះបីជាខ្ញុំមិនបានស្នាក់នៅទីនោះយូរ តែខ្ញុំពិតជាចាប់អារម្មណ៍ជាខ្លាំង ជាពិសេសនោះជាមួយបរិយាកាសប្រវត្តិសាស្ត្រនៃសំណង់បែបសម័យអាណានិគមបារាំង។ នេះគឺជាកន្លែងដ៏អស្ចារ្យសម្រាប់ការថតរូប"៕



Stitching Blue Fringe V-Neck Black Halter Fishtail Dress **Eric Raisina** $1150.00, Gem Flowery Earrings **LE MARAIS** $120.00, Braided Metal Bracelet **Ambre**, Blue & Pink Braided Strap Heel Sandals **e.pse** $49.00



Deep Maroon Wrap Satin Slit Dress **e.pse** $163.00,. Golden Fringe Earrings **LE MARAIS** $35.00, Metal Chain Belt Fuctioning as a Bracelet **e.pse** $57.00